# ផែនការមីក្រូៈ ករណីសិក្សា

MICRO PLANNING

ករណីសិក្សានេះផ្អែកលើការងាររបស់ PRIA ជាផ្នែកពង្រឹងស្ថាប័ន Panchayati Raj (ស្ថាប័នអត្តា អភិបាលកិច្ចមូលដ្ឋាននៅជនបទ) នៅខេត្តហាមាចាល់ ប្រទេសឥណ្ឌា ។

វិសោធនកម្មរដ្ឋធម្មនុញ្ញទី៧៣ បានបំលែងមុខមាត់នៃ Panchayat នៅទូទាំប្រជាជាតិ ពីស្ថានភាពជាភ្នាក់ងារអនុវត្តនានានៃរដ្ឋាភិបាលរបស់រដ្ឋ ទៅស្ថានភាព ដែលខ្លួនអាចចាប់ផ្តើមបំពេញមុខងារជាអង្គនៃរដ្ឋាភិបាលមូលដ្ឋាន ។ Panchayat សព្វថ្ងៃ មានអត្តភាពធានាដោយរដ្ឋធម្មនុញ្ញ និង សច្ចាប័នដើម្បីរៀបចំផែនការនានាសម្រាប់ " ការអភិវឌ្ឍសេដ្ឋកិច្ច និងយុត្តិធម៌សង្គម " ។ ដោយមានការអភិវឌ្ឍទាំងឡាយនេះ នៅពីក្រោយដំនើរការនៃការរៀបចំផែនការ ពីក្រោមទៅលើ ក៏ត្រូវ បានទទួលនូវចំនាប់ចិត្តសារជាថ្មី ។

ឈរលើមូលដ្ឋាននេះនិង ទស្សនៈដែលថា ការរៀបចំរៀបចំផែនការពីក្រោមឡើងទៅលើ ឬ ផែនការមីក្រូ ជាមូលដ្ឋាននៃអត្តាភិបាលកិច្ចមូលដ្ឋាន ការផ្តួចផ្តើមគំនិតមួយត្រូវបានលើកឡើងដោយ PRIA និង អង្គការនៅមូលដ្ឋានមួយ គឺមជ្ឈមណ្ឌលបច្ចេកវិជានិងអភិវឌ្ឍនៅជនបទ RTDC ដើម្បីជួយសម្រួលដំនើរការ រៀបចំផែនការក៏រីត Panchayat ដោយមានចូលរួមពីប្រជាជន ។ នាក់សំរួលទាំងឡាយចាប់ ផ្តើមដំណើរការរៀបចំផែនការនៅ Panchayat **កេហារ** ដែលស្ថិតនៅប្រហែល២៥ គ.ម **ពីម៉ាន់ឌី** ទីបញ្ជាការ នៃស្រុកម៉ាន់ឌី ប្រទេសហ៊ីម៉ាចាល ។ Panchayat នេះត្រូវបានបែងចែកជា១១វ៉រដ៏ ward ហើយមាន ៦ភូមិហើយមានប្រជាជន៤០០០នាក់ និង ប្រហែល៩០០គេហព័ន្ធ ។

ដំណាក់ការដំបូងនៃដំនើរការធ្វើផែនការ គឺសំខាន់បំផុត ព្រោះវាជាគ្រិះសម្រាប់សកម្មភាពទាំងអស់ទៅអនាគត ។ ការជ្រើសរើសយក Panchayat កេហារ គឺភាគច្រើនដោយសារវត្តមាននៃ RTOC ដែលមានអ្នកសម្របសម្រួលជាប្រធាននៃ Panchayat ផងដែរ ។ នេះលើកគុណភាព និងលទ្ធិភាពដើម្បីបង្កើតការទាក់ទងគ្នាជាមួយសហគមមូលដ្ឋាននៅទីនោះ ។

ដោយហេតុថាការរៀបចំផែនការមីក្រូត្រូវការការពាក់ព័ន្ធនៃសមាគមមូលដ្ឋាន គឺមានសារសំខាន់ណាស់ដែលត្រូវផ្តល់ហេតុផលជំរុញលើកទឹកចិត្តតាំងពីដើមដំបូង ។មាគ៌ាដែលបានប្រកាន់យកគឺបង្កើត ក្រុមស្នូលដែលត្រូវធ្វើការផ្ទាល់ជាមួយសហគម ។

សិក្ខាសាលាមួយបានរៀបចំឡើងសម្រាប់ក្រុមស្នូលដាក់សញ្ញាសម្រាប់ការចាប់ផ្តើមជាផ្លូវការនៃលំហាត់។ បន្ទាប់ពីនេះ ការប្រជុំនានាត្រូវបានកោះហៅជាមួយប្រធានរបស់ Panchayat ទាំងឡាយនិងក្នុងតំបន់នយោបាយនិមួយ ៗ។

តាមរយៈសកម្មភាពទាំងឡាយនេះ គឺគេមានលទ្ធិភាពបង្កើតការដឹងលឺមួយចំនួនធំអំពីដំនើរការធ្វើផែនការ និង អ្វីពីថា តើធ្វើយ៉ាងណាដើម្បីអោយប្រជាជនចូលពាក់ព័ន្ធនិងវា ។នៅពេលជាមួយគ្នានោះ អ្នកស្ម័គ្រចិត្តពីរនាក់ត្រូវបានកត់សំគាល់សម្រាប់វ៉ិរដ៏និមួយៗ ដែលទទួលបាននូវការបណ្តុះបណ្តាលបន្ថែម ។

នៅក្នុងការប្រជុំក៏រិតវ៉ិរដ៏ ដែលមានចំនួនប្រជាជនច្រើនចូលរួមជាពិសេសស្រ្តី បរិក្ខាអប់រំនានា ក្នុងទម្រង់ជាផ្ទាំងគំនូរ សៀវភៅតូច ត្រូវបានចែកជូនអ្នកមានវត្តមាននៅទីនោះ។

នៅដំនាក់កាលដំបូងនៃការកសាងការទំនាក់ទំនងជាមួយប្រជាជន និង បង្កើតចំណាប់ ចិត្តក្នុងចំនោមគេទាំងអស់គា ដំណាក់ការបន្ទាប់មកគឺត្រូវយល់ដឹង ពីស្ថានភាពដែលកំពុងមានក្នុងតំបន់តាមរយ ការប្រមូលទិន្នន័យជាប្រព័ន្ធនិង ការធ្វើផែនទីធនធាន ។

នេះគឺសំខាន់ព្រោះថាដើម្បីធ្វើផែនការសម្រាប់អនាគតចាំបាច់គឺត្រូវដឹងពីភាពពិតបច្ចុប្បន្ន។ ការផ្តោតនៃដំនាក់កាលនេះ គឺធ្វើឱ្យសមាជិកសហគមសញ្ជឹងគិតអំពីភាពពិតជាឯកត្តជនរបស់គេទាំងឡាយ ដោយប្រើការផ្សំគ្នានៃវិធីសាស្រ្តប្រមូលទិន្នន័យនានា។

ដោយសារតារាងទិន្នន័យត្រូវបានធ្វើដោយអ្នកសំរួលនានា នោះមានការគិតឃើញថាសំខាន់ណាស់ដែលត្រូវចែករំលែកអ្វីៗដែលឃើញទាំងអស់ជាមួយសហគមភាមក្រោយមក។ មាគ៌ានៃការប្រជុំក៏រិតភូមិត្រូវទទួលបានចំនូលចិត្ត ហើយនេះបង្កលទ្ធភាពឱ្យអ្នកសំរួលធ្វើចលនាពីភាពពិត នានានៃ " ឯកត្តជន " ទៅ " ក្រុម "។

ការផ្តោតនៃការប្រជុំនេះគឺធ្វើឱ្យសមាជិកសហគមយល់ដឹងពីស្ថានភាពសង្គមសេដ្ឋកិច្ចរបស់ភូមិទាំងមូល និងចំណោទចំបងៗនៅក្នុងនោះ។

កិច្ចការនេះត្រូវបន្តដោយដំណាក់ការនៃការធ្វើវិភាគទៅលើចំណោទរបស់សហគម និងការកត់សម្គាល់អាទិភាពនៃការអភិវឌ្ឍទាំងឡាយ។ តាមរយៈការប្រជំក៏រិតភូមិតៗគ្នា មួយជន្លាស គេទាំងឡាយត្រូវបានលើកទឹកចិត្តឱ្យវិភាគចំណោទនានានៅក៏រិត ឯកត្តជន ភូមិ និង Panchagat ហើយរៀបជាចំនាត់ថ្នាក់មុនក្រោយ ទៅតាមការទទួលដឹងឮនូវសេចក្តីត្រូវការចាំបាច់ និង អាទិភាពទាំងឡាយ។

សមាជិកសហគមទាំងឡាយ នាំគ្នាបន្តឆ្ពោះទៅការកត់សម្គាល់កិច្ចអភិវឌ្ឍនានា និងដែលអាចធ្វើបានដែលអាចដោះស្រាយសេចក្តីត្រូវការទាំងឡាយនេះ។

ដំណាក់ការនេះ ត្រូវការការណែនាំខ្លះដើម្បីឱ្យសមាជិកសហគមអាចជ្រើសរើសយកយុទ្ធសាស្ត្រត្រឹមត្រូវសម្រាប់ការអភិវឌ្ឍ។ ការផ្តោតត្រូវបានដាក់ទៅលើវិភាគទានរបស់ប្រជាជន (ក្នុងទិដ្ឋភាពនៃពលិកម្ម បរិក្ខារ និងប្រាក់កាស )សម្រាប់ធ្វើអោយភូមិកាន់តែល្អឡើង។ ការប្រើធនធាននានាដែលរកបាន នៅនិងកន្លែង ឱ្យអស់លទ្ធភាព ក៏ត្រូវបានសង្កត់លើផងដែរ ។ នៅក្នុងដំនាក់ការនេះគណកម្មាធិការ (ដែលមានអ្នកឯកទេសបច្ចេកទេសនានាបុរស ស្ត្រី ។ល។) គឺដើម្បីជួយក្នុងការបង្កើត និង អនុវត្តផែនការអភិវឌ្ឍ ។ បន្ទាប់ពីនេះ វីស៊ីឱ រៀបចំការប្រជុំសម្រាប់ភូមិដើម្បីតែង និងធ្វើការងារបង្ហើយផែនការនានា បន្ទាប់ពីប្រជាជន។ ផែនការទាំងនោះនិងត្រូវដាក់ជូនទៅ Gram Panchayat ដែលយកផែនការ ទាំងអស់ មកបញ្ចូលគ្នាដើម្បីបង្កើតផែនការក៏រិត Panchayat ដែលត្រូវទទួលការយល់ព្រមពីប្រជាជន នៅក្នុងការប្រជុំ Gram Sabha (ក្រុមប្រឹក្សាភូមិ )។ ការប្រជុំនៃ Gram Sabha គឺជាបញ្ញត្តិអម បង្ខំមួយនៃរដ្ឋធម្មនុញ្ញ ហើយត្រូវបានកោះហៅពីរដងក្នុងមួយឆ្នាំ។